# ស្វែងយល់ពីពិធីពិសាខបូជា

*ដោយ* : **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ពិសាខបូជា ជាពិធីបុណ្យធំមួយ ក្នុងព្រះពុទ្ធសាសនា ដែលប្រទេសកម្ពុជា បានចាត់ទុកជាបុណ្យជាតិ និងជាឈ្មោះនៃពិធីបុណ្យ ឬការធ្វើសក្ការបូជាក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ដែលជាថ្ងៃព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ប្រសូត ទ្រង់បានត្រាស់ដឹង ទ្រង់រលត់ខន្ធចូលកាន់បរិនិព្វាន ពោលគឺជាធ្វើការរំឭកដល់ព្រះគុណរបស់ព្រះអង្គ ឬជាការបូជាពិសេសសម្រាប់ពុទ្ធសាសនិកជន គឺទាំងបព្វជិតទាំងគ្រហស្ថតែងតែនាំគ្នាប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ហើយដែលយើងអាចរាប់ថាជាបុណ្យសម្រាប់ពុទ្ធសាសនា។*




*ជាងនេះទៀត ប្រទេសជិត២០០ ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ បានអនុម័ត និងទទួលស្គាល់បុណ្យនេះជាបុណ្យអន្តរជាតិ អស់រយៈពេលជាង២០មកហើយ តាំងពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៩ មក។*

*បើតាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ* **ជួត ណាត** *បានបកស្រាយថា៖ ពិសាខបូជា នាមសព្ទ (បា.វិសាខ+បូជា) ឈ្មោះពិធីបុណ្យ ឬការធ្វើសក្ការបូជាក្នុងថ្ងៃពេញបូណ៌មីខែពិសាខ ជាថ្ងៃដែលព្រះសក្យមុនីសម្មាសម្ពុទ្ធ ទ្រង់ប្រសូត, ទ្រង់បានបរមាភិសម្ពោធិ, ទ្រង់រលត់ខន្ធចូលកាន់បរិនិព្វាន; ធ្វើរំឭកដល់ព្រះគុណរបស់ព្រះអង្គ, ជាការបូជាពិសេសមួយយ៉ាង សម្រាប់ពុទ្ធសាសនិកជន ទាំងបព្វជិត ទាំងគ្រហស្ថ*

នាំគ្នាធ្វើរាល់ឆ្នាំ, រាប់ថាជាបុណ្យសម្រាប់ពុទ្ធសាសនា។ ថ្ងៃពិសាខបូជា, ធ្វើពិសាខបូជា។[1]

ព្រះពុទ្ធ មានព្រះនាមដើមថា **សិទ្ធត្ថ** (អានថា **សិត-ថ័ត**) ដែលជាព្រះរាជបុត្រារបស់ព្រះនាង **សិរិមហាមាយា** និងព្រះបាទ **សុទ្ធោទនៈ**។ ព្រះអង្គ ត្រូវបានគេហៅព្រះនាមជាច្រើនទៀត ដូចជា **ព្រះសម្មាសម្ពុទ្ធ ព្រះសមណគោតម ព្រះជិនស្រី ព្រះសក្យមុនី ព្រះបរមគ្រូ ព្រះសាស្តា** ជាដើម។

ព្រះអង្គ ទ្រង់ប្រសូត នៅថ្ងៃសុក្រ **ពេញបូណ៌មី ខែវិសាខ** ឆ្នាំច មុនគ្រិស្តសករាជចំនួន**៦២៣ឆ្នាំ**។ ព្រះអង្គទ្រង់ប្រសូត្រនៅព្រៃលុម្ពិនី (ព្រៃសាលវ័ន) ជាចន្លោះនគរទាំងពីរ គឺនគរកបិលពស្តុ និងនគរ ទេវទហៈ ហើយមានសេចក្ដីអស្ចារ្យយ៉ាងនេះគឺ មានទរទឹកក្ដៅ១ ទរទឹកត្រជាក់១ ហូរធ្លាក់ពីអាកាសមក លាងជម្រះព្រះមន្ទិលនៃគភ៌ មានសុទ្ធាវាសមហាព្រហ្ម៤អង្គ យកបណ្ដាញមាសមកទទួលទ្រព្រះពោធិសត្វ មហារាជទាំង៤ ទទួលយកពីមហាព្រហ្មទៀត ពួកស្រីស្នំទទួលយកពីមហារាជទៅទៀត ព្រះពោធិសត្វ ចុះពីដៃស្រីស្នំ ហើយទ្រង់ឈរលើផែនដីដោយព្រះបាទទាំងគូ។ មហាព្រហ្មយកស្វេតច្ឆ័ត្របាំងថ្វាយ សុយាម ទេវរាជយកវាលវិជនីមកបក់ថ្វាយ ទេវបុត្រ១អង្គកាន់កែវ៧ប្រការ ទេវបុត្រ១អង្គកាន់សុវណ្ណបាទុកា (ស្បែកជើងមាស) ទេវបុត្រ១អង្គកាន់គ្រឿងរាជកកុធភ័ណ្ឌ (គ្រឿងសម្រាប់រាជ្យ) ទាំង៥ប្រការ គឺ មកុដ១ ព្រះខាន់១ ស្វេតច្ឆ័ត្រ១ សុពណ៌បាទ១ វាលវិជនី១។ មនុស្សទាំងឡាយដែលនៅក្នុងទីប្រសូតិទាំងអស់គ្នា សុទ្ធតែបានឃើញសេចក្ដីអស្ចារ្យទាំងនោះជាក់ច្បាស់នឹងភ្នែក។ កាលព្រះពោធិសត្វប្រសូត្ររួចហើយ ចុះពី ដៃស្រីស្នំ ទ្រង់យាងទៅបាន៧ជំហាន ហើយឈប់ឈរនៅនឹងរួចបែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ ទ្រង់បន្លឺ អសត្វវាចា (សំដីរបស់សប្បុរស) ថា "**អគ្គោហមស្មី លោកស្ស សេដ្ឋោហមស្មី លោកស្ស ជេដ្ឋោហមស្មី លោកស្ស**"។ [2]

នៅពេលព្រះអង្គមានព្រះជន្ម២៩ព្រះវស្សា ព្រះអង្គយាងទៅសាងព្រះផ្នួស។

[1] ជួន ណាត ***វចនានុក្រមខ្មែរ***

[2] មិន ឃិន ***ប្រជុំបុណ្យក្នុងព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ខ្មែរ*** ក្រសួងធម្មការនិងសាសនា ឆ្នាំ២០១០ ទំព័រ៨។

ក្រោយពីទ្រង់បានក្លាយខ្លួនជាអ្នកបួសអស់រយៈពេល៦ឆ្នាំ ព្រះអង្គក៏បានត្រាស់ដឹងជាព្រះពុទ្ធ នៅថ្ងៃ**ពុធ ពេញបូណ៌មី ខែវិសាខ** ឆ្នាំរកា នាវេលា**ទៀបភ្លឺ** ហើយទ្រង់ចូលបរិនិព្វាន នៅថ្ងៃ**អង្គារ ពេញបូណ៌មី ខែវិសាខ** ឆ្នាំ**ម្សាញ់** ក្នុងព្រះជន្មាយុ **៨០ព្រះវស្សា** ហើយបើគិតរហូតមកដល់ពេលនេះ ព្រះអង្គរលត់សង្ខារអស់រយៈពេល២៥៦៨ឆ្នាំមកហើយ។

បើយើងធ្វើការសង្កេតទៅលើថ្ងៃប្រសូត ត្រាស់ដឹង និងបរិនិព្វានរបស់ទ្រង់ គឺចំក្នុងថ្ងៃតែមួយ គឺថ្ងៃ**១៥កើត ពេញបូណ៌មី ខែវិសាខ** ដូចគ្នា ខុសតែឆ្នាំប៉ុណ្ណោះ។ ដូច្នេះ បុណ្យវិសាខបូជា ក៏តំណាងឱ្យថ្ងៃទាំងបី (ប្រសូត ត្រាស់ដឹង និងបរិនិព្វាន) នេះឯង។

ម្យ៉ាងវិញទៀត បុណ្យវិសាខបូជា គេរាប់ជាថាជាបុណ្យមួយយ៉ាងធំក្នុងព្រះពុទ្ធសាសនា ជាពុទ្ធានុស្សរណកិច្ចដ៏សំខាន់ សម្រាប់រំឭកដល់ព្រះពុទ្ធសមណគោត្តម បរមគ្រូ នាថ្ងៃពេញបូណ៌មី ថ្ងៃ១៥កើត ខែវិសាខ ដែលពុទ្ធសាសនិកទាំងព្រះសង្ឃ ទាំងគ្រហស្ថ តែងធ្វើសក្ការបូជាប្រកបដោយជំនឿថាជាមហាកុសលដ៏ប្រសើរ។

សូមបញ្ជាក់ថា ការប្រារព្ធពិធីបូជានាថ្ងៃ១៥កើត ខែវិសាខនេះ អាស្រ័យដោយលោកអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា បានកំណត់ទុកក្នុងគម្ពីរបឋមសម្ពោធិ ថាជាមហាមង្គលអភិលក្ខិតកាល[៣] គឺជាថ្ងៃមហាមង្គល ត្រូវនឹងថ្ងៃដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់ប្រសូតចាកឧទរមាតា ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ និងទ្រង់រំលត់ខន្ធចូលកាន់ព្រះនិព្វាន ពោលគឺទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាន សុទ្ធតែក្នុងថ្ងៃពេញបូណ៌មី ខែវិសាខទាំងអស់ ខុសតែឆ្នាំ។

ព្រះអង្គទ្រង់ប្រសូតិនៅ ថ្ងៃ**សុក្រ ពេញបូណ៌មី ខែវិសាខ** ឆ្នាំច វេលាជិតថ្ងៃត្រង់ មុនពុទ្ធសករាជ៨០ឆ្នាំ នា**ឧទ្យានលុម្ពិនី** ព្រៃសាលព្រឹក្ស ចន្លោះនគរទាំងពីរ គឺនគរ**កបិលពស្តុ** និងនគរ**ទេវទហៈ** ហើយដែលឧទ្យានលុម្ពិនី សព្វថ្ងៃនេះស្ថិតនៅក្នុងប្រទេស**នេប៉ាល់** មានចម្ងាយ**២៧គ.ម.** ពីព្រំដែននៃប្រទេស**ឥណ្ឌា**។

[៣] កាលឬសម័យដែលគេកំណត់ទុក។

ព្រះពុទ្ធទ្រង់បានត្រាស់ដឹង នៅថ្ងៃ **ពុធ ពេញបូណ៌មី ខែវិសាខ** ឆ្នាំ**រកា** វេលាជិតភ្លឺ មុនពុទ្ធសករាជ**៤៥ឆ្នាំ** ក្នុងព្រះជន្ម **៣៥ឆ្នាំ**។ ទីស្ថានដែលព្រះអង្គបានត្រាស់ដឹងជាសព្វញ្ញុពុទ្ធ ហៅថា**ពុទ្ធគយា** ស្ថិតនៅក្នុងរដ្ឋ**ពីហា** ( Bihar ) ប្រទេស**ឥណ្ឌា**។

ព្រះពុទ្ធទ្រង់បរិនិព្វាន ក្នុងថ្ងៃ**អង្គារ ពេញបូណ៌មី ខែវិសាខ** ឆ្នាំ**ម្សាញ់** វេលាជិតបែកបច្ចូសម័យ[4] មុនពុទ្ធសករាជ១ថ្ងៃក្នុងព្រះជន្ម៨០ឆ្នាំ គត់ ចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងក្រុង**កុសិនារា** ដែលសព្វថ្ងៃនេះទីក្រុង**កុសិនារា** ត្រូវបានគេហៅថា ក្រុង**កុសិនាហ្គារ៍** (កុសិនគរ) ឬហៅថាក្រុង**កាស្យា** ស្ថិតនៅក្នុងរដ្ឋ**ឧត្តរប្រទេស** របស់ឥណ្ឌា ។

ជាប្រពៃណី បុណ្យវិសាខបូជា គេតែងនាំគ្នាធ្វើក្នុងពេលរាត្រី ព្រោះតម្រូវទៅតាមពាក្យថា **បុណ្ណមី** មានសេចក្តីថា **ខែពេញបូណ៌មី** ហើយការប្រារព្ធពិធីក្នុងពេលរាត្រីនេះ អាស្រ័យដោយលក្ខណៈងាយស្រួល២យ៉ាង គឺម្យ៉ាងដើម្បីនឹងបានឱកាសអុជគ្រឿងប្រទីបផ្កាលា បូជាភ្លើងអគ្គិសនីឱ្យភ្លឺរុងរឿងរន្ទាលប្រាលឆ្អៅផង និងម្យ៉ាងទៀត ដើម្បីបើកឱកាសឱ្យពុទ្ធបរិស័ទបានជួបជុំគ្នា ដ៏ច្រើនកុះករទាំងប្រុសទាំងស្រីអាចបំពេញកុសលកម្មនេះ ដោយសប្បាយរីករាយ ព្រោះពេលយប់ជាពេលទំនេរផង។

តាមទំនៀមទម្លាប់ប្រពៃណីពុទ្ធបរិស័ទ ទាំងបព្វជិត ទាំងគ្រហស្ថ ត្រូវដើរដង្ហែប្រទក្សិណ ៣ជុំសិនមុននឹងចូលព្រះវិហារ ហើយគេយកទេយ្យវត្ថុរៀបចំដាក់នៅមុខពុទ្ធរូប រួចអុជទៀនធូបបូជាផ្កាភ្ញីផ្សេងៗ ហើយនាំគ្នានមស្ការព្រះរតនត្រ័យ សមាទានសីល ស្តាប់ពុទ្ធមន្ត ស្តាប់ធម៌ទេសនា អំពី ពុទ្ធប្បវត្តិ តាំងពីដើមរហូតដល់ចប់ ទើបព្រះសង្ឃ និងឧបាសក ឧបាសិកាសូត្រធម៌បទផ្សេងៗដូចជា នមោ៨បទ ឋាន ធំ៨កន្លែងជាដើម ហើយនៅយប់នោះគេធ្វើរហូតទល់ភ្លឺ តាមលទ្ធភាពវត្តនីមួយៗ ដើម្បីឱ្យមានបសាទសទ្ធា ចំពោះព្រះរតនត្រ័យកាន់តែខ្លាំងក្លាឡើង។

---

[4] បច្ចូសសម័យ (ប៉័ច-ចូស) នាមសព្ទ (បា.; សំ. ប្រត្យុមសិ ឬ ប្រត្យូម "កាលជាទីកម្ចាត់នូវងងឹត") ពេលបំព្រាង គឺវេលាភ្លឺឯកើត (មុនបុព្វណ្ហសម័យ) វេលាបែកបច្ចូស ( ហៅថាបច្ចូសកាល ឬបច្ចូសសម័យ ( ប៉័ច-ចូសៈ —ក៏បាន ) ។

## ១. ប្រវត្តិបុណ្យ និងប្រភពកំណើតនៃពិធីបុណ្យវិសាខបូជា

### ១.១. ប្រវត្តិបុណ្យពិសាខបូជា

*ពុទ្ធបរិស័ទក្នុងប្រទេសទាំងឡាយដែលរាប់អានព្រះពុទ្ធសាសនា នាំគ្នាធ្វើវិសាខបូជា នៅថ្ងៃពេញបូណ៌មី ខែពិសាខ រៀងៗមកតាំងពីបុរាណកាល ។ តាមការស្រាវជ្រាវគេបានដឹងថា បុណ្យវិសាខបូជា ទំនងជាធ្វើនៅក្រោយពុទ្ធបរិនិព្វានច្រើនរយឆ្នាំ។ គេថាប្រទេសឥណ្ឌា និងប្រទេសលង្កា បានប្រារព្ធពិធីបុណ្យនេះយូរយារណាស់មកហើយ។ ចំណែកប្រទេសសៀម និងប្រទេសខ្មែរទើបនឹងចាត់ចែងធ្វើនៅគ្រិស្តសតវត្សទី១៩។ នៅក្នុងប្រទេសកម្ពុជា បុណ្យវិសាខបូជា តាមដែលចាស់ទុំ អ្នកមុខអ្នកការទាំងឡាយតំណាលតៗគ្នា បានឱ្យដឹងថា គេបានផ្ដើមធ្វើក្នុងរជ្ជកាលព្រះបាទសម្ដេច **ព្រះហរិរក្សរាមា** (ព្រះអង្គឌួង) ដែលគង់នៅក្រុង**ឧត្ដុង្គ** ក្នុងពុទ្ធសករាជ ២៣៩៧ គ្រិស្តសករាជ **១៨៥៤ ដោយមហាប៉ាន** ដែលស្ដេចសៀម បានបញ្ជូនមកកាន់ឧត្ដុង្គ តាមសំណើព្រះបាទ អង្គឌួង។ តាំងពីពេលនោះមក ទំនៀមនេះក៏ទេងតែត្រូវបានប្រារព្ធធ្វើជានិច្ចកាល លើកលែងតែសម័យកម្ពុជាប្រជាធិបតេយ្យដែលជាសម័យដ៏យង់ឃ្នងលុបបំបាត់ជំនឿសាសនារបស់សង្គមជាតិ។*

### ១.២. ប្រភពកំណើតនៃបុណ្យវិសាខបូជា

***តើប្រទេសណាជាអ្នកចាប់ផ្ដើមធ្វើនូវបុណ្យវិសាខបូជានេះមុនគេ? តើប្រទេសកម្ពុជាយើងចាប់ផ្ដើមធ្វើបុណ្យវិសាខបូជាពីត្រឹមពេលណាមក?***

*នៅពេលដែលពុទ្ធបរិស័ទក្នុងប្រទេសគោរពប្រតិបត្តិពុទ្ធសាសនាទាំងឡាយ បានជ្រួតជ្រាបអំពីអភិលក្ខិតកាលនិយម គឺថ្ងៃប្រសូត ត្រាស់ដឹង និងបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធថា សុទ្ធតែនៅថ្ងៃពេញបូណ៌មី ខែវិសាខ ហើយក៏នាំគ្នាធ្វើពិធីវិសាខបូជាជារៀងរហូតតាំងពីបុរាណកាលមក។ តាមការស្រាវជ្រាវឃើញថា ការធ្វើពិធីវិសាខបូជានេះ ពុំមែនធ្វើក្រោយព្រះពុទ្ធទ្រង់បរិនិព្វានទៅថ្មីៗនោះទេ គឺធ្វើក្រោយពេលដែលព្រះពុទ្ធបរមគ្រូទ្រង់បរិនិព្វានកន្លងទៅជាច្រើនរយឆ្នាំ។*

*ចំណែកនៅប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនា បានមកប្រតិស្ឋានតាំងពីដំបូង ហើយស្ថិតនៅជាប្រទេសមានឥស្សរភាពជាយូរណាស់មកហើយ តែបើ*

តាមការស្រាវជ្រាវ ពិនិត្យមើលនៅក្នុងព្រះរាជពង្សាវតារ ឬក្នុងសេចក្តីកំណត់ហេតុផ្សេងៗតាំងពីសម័យនគរភ្នំ"ហ្វូណន" រហូតមកដល់សម័យក្រុងលង្វែក មិនប្រាកដថាមានទំនៀមធ្វើវិសាខបូជានេះឡើយ។ តែបើយោងទៅលើសេចក្តីថា ព្រះពុទ្ធសាសនាលទ្ធិលង្កា ក៏បានផ្សាយចូលមកកម្ពុជរដ្ឋក្នុងសម័យជាមួយគ្នានឹងក្រុងសុខោទ័យ គួរសន្និដ្ឋានបានថា មានទំនៀមធ្វើវិសាខបូជារួចមកហើយ ដូចជាប្រទេសថៃដែរ តែកម្ពុជាយើងពុំឃើញមានឯកសារជាភស្តុតាង ឬក៏មានដែរ តែត្រូវរលាយសាបសូន្យអស់ទៅ។ លុះចំណេរយូរលង់មក គឺក្នុងសម័យក្រុងអយុធ្យាខាងថៃ និងក្នុងសម័យក្រុងលង្វែកខាងខ្មែរ ទំនៀមទម្លាប់ធ្វើវិសាខបូជា ត្រឡប់ជាសាបសូន្យទៅវិញ ដូចជាភ្លេចសូន្យឈឹងទាំងស្រុង ព្រោះមិនមានប្រាកដក្នុងឯកសារណាមួយថាបានធ្វើឡើយ។

តើទាំងនេះព្រោះហេតុអ្វី?

តាមការសន្និដ្ឋាន ក៏បានបញ្ជាក់ឱ្យឃើញថា ៖

១- ព្រោះព្រះសង្ឃដែលនិមន្តមកអំពីលង្កានោះផុតរលត់អស់ទៅ

២- ព្រោះរឿងបឋមសម្ពោធិកថា ស្តីអំពីរឿងពុទ្ធប្រវត្តិក្នុងពេលនោះ មានតែជាភាសា បាលី ហើយនៅរាត់រាយក្នុងគម្ពីរព្រះត្រៃបិដកខ្លះ ក្នុងអដ្ឋកថាខ្លះ ពុំទាន់ចងក្រងរួបរួម និងពុំទាន់បានប្រែរៀបរៀងជាភាសាសម្រាយជាតិនៅឡើយ។ រីឯអ្នកស្រុកក៏ពុំទាន់ជ្រួតជ្រាបជាទូទៅគ្រប់គ្នា មានតែព្រះសង្ឃដែលចេះភាសាបាលី ទើបអាចដឹងបានខ្លះ ព្រោះហេតុនេះហើយទើបពិធីបុណ្យវិសាខបូជា ត្រូវបានសាបសូន្យទៅវិញ។

ចំណេរក្រោយមកប្រទេសថៃក្នុងសម័យក្រុងទេព"បាងកក" តាមសេចក្តីដែលមានក្នុងសៀវភៅ**ព្រះរាជពិធីស៊ិបសងឿនថា** ក្នុងរជ្ជកាលទី ២ ក្នុងឆ្នាំ ឆ្លូវ នព្វស័ក ពុទ្ធសករាជ២៣៦០ គ្រិស្តសករាជ ១៨១៧ ទើបកើតមានពិធីវិសាខបូជា ដោយពេលនោះ មានសម្តេចព្រះសង្ឃរាជ១ព្រះអង្គ ព្រះនាម "**មី**" នៅវត្តរាជបូរណៈ បានមកថ្វាយព្រះពរដោយស្នើសុំឱ្យទ្រង់ធ្វើវិសាខបូជាជាដំបូង។

ចំណែកនៅប្រទេសកម្ពុជាវិញ ក្នុងសម័យជាមួយគ្នានេះ ប្រហែលជាមិនទាន់មានទំនៀមធ្វើនៅឡើយ ដោយហេតុថា ការ

ធ្វើវិសាខបូជានៅប្រទេសថៃក្នុងជំនាន់នោះ នៅមិនទាន់មាំមួននៅឡើយ ទាំងគម្ពីរបឋមសម្ពោធិ ដែលសម្រាយប្រើប្រាស់ក្នុងការនេះ ក៏មិនទាន់មាននៅឡើយដែរ។

ឯក្នុងគម្ពីរបឋមសម្ពោធិ ជារឿងពុទ្ធប្រវត្តិតំណាលរឿងចាប់ផ្ដើមតាំងពីព្រះអង្គចុះចាកស្ថានតុសិតទេវលោក មកយកកំណើតជាព្រះរាជបុត្រនៃព្រះបាទ**សុទ្ធោទនៈ** និងព្រះនាង**សិរិមហាមាយាទេវី** នៅក្នុងនគរ**កបិលពស្តុ** ក្នុង**មជ្ឈិមប្រទេស** រឿងដរាបដល់ព្រះអង្គទ្រង់បានត្រាស់ជាអង្គព្រះសម្ពុទ្ធ និងប្រកាសសម្ដែងធម៌ប្រោសសត្វលោក ហើយសម្ដេចទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វានជាទីបំផុត។

គម្ពីរបឋមសម្ពោធិនេះ អ្នកប្រាជ្ញតាក់តែងឡើងនូវសេចក្ដីសម្រាយសម្រាប់ទេសនានៅក្នុងបុណ្យវិសាខបូជា ព្រោះថាការដែលនាំយកប្រវត្តិរបស់រឿងនេះមកសម្ដែង ក៏ដើម្បីជាកស្ដុតាងបញ្ជាក់ឱ្យដឹងថាបុណ្យវិសាខបូជាកើតឡើងពិតប្រាកដនោះពីត្រឹមពេលដែលកើតគម្ពីរនេះឡើង។ គម្ពីរនេះកើតមានប្រាកដឡើងនៅប្រទេសថៃស្ថិតក្នុងរជ្ជកាលព្រះបាទសម្ដេច**ព្រះណាំងក្លាវ** "រជ្ជកាលទី៣" ជាដំបូង ហើយក្នុងជំនាន់នោះ គម្ពីរនេះមាន២ប្រភេទគឺ ៖

១- គម្ពីរបឋមសម្ពោធិសង្ខេប មានចំនួន២០បរិច្ឆេទ តែមិនមានឈ្មោះអ្នកនិពន្ធពិតប្រាកដនោះទេ ប្រហែលជានិពន្ធឡើងក្នុងរជ្ជកាលទី២។

២- គម្ពីរបឋមសម្ពោធិវិត្ថារ ជាភាសាមគធៈមានចំនួន២១ខ្សែ ឬ ៣០បរិច្ឆេទទាំងជាភាសាបាលី និងសម្រាយ។ សម្ដេច**ព្រះណាំងក្លាវ** ទ្រង់អារាធនាសម្ដេចក្រុមព្រះបរមានុជិត ជិនោរសសង្ឃរាជ គង់នៅវត្តព្រះជេតព័ន ក្នុងក្រុងទេពឱ្យនិពន្ធឡើង។

សម្ដេចក្រុមព្រះអង្គនេះ បានរួបរួមសេចក្ដីចេញពីគម្ពីរផ្សេងៗ និងនិពន្ធបន្ថែមឡើងខ្លះ ក្នុងពុទ្ធសករាជ ២៣៨៧ គ្រិស្ដសករាជ ១៨៤៥។

ចំណែកប្រទេសខ្មែរយើង គម្ពីរបឋមសម្ពោធិជាភាសាមគធៈ មានចំនួន២១ខ្សែ ឬ ៣០បរិច្ឆេទ។

គម្ពីរជាសម្រាយមាន៣បែបគឺ៖

១. ហៅថា គម្ពីរបឋមសម្ពោធិសង្ខេប ឬហៅថា "បឋមត្រាស់" មានចំនួន ៥-៦ ខ្សែ

ឬមួយខ្សែចប់ ពណ៌នាសេចក្តីតាំងពីព្រះអង្គយាងចុតិចាកតុសិត មកចាប់បដិសន្ធិជាព្រះឱរសនៃព្រះបាទ**សុទ្ធោទនៈ** និងព្រះនាង**សិរិមហាមាយាទេវី** រហូតមកត្រឹមព្រះអង្គចេញទ្រង់ព្រះផ្នួស បានត្រាស់ជាព្រះពុទ្ធ។ អត្ថបទនេះមិនដឹងជាអ្នកណាជាអ្នកនិពន្ធ ហើយនិពន្ធពីក្នុងពុទ្ធសករាជណាទេ។ តែតាមការសង្កេតមើលពាក្យពេចន៍ក្នុងគម្ពីរនោះ ឃើញថាមិនជាចាស់ណាស់ណានោះទេ យ៉ាងយូរណាស់ត្រឹមសម័យក្រុងឧដុង្គខាងដើម។ គម្ពីរនេះគេច្រើនប្រើពាក្យសម្រាយទេសនាក្នុងពិធីបុណ្យអភិសេកព្រះពុទ្ធរូបផង។

២. ហៅថា "គម្ពីរបឋមសម្ពោធិវិត្ថារ" មានចំនួន៣០បរិច្ឆេទ។ គម្ពីរនេះ សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ **ជួនណាត** (កាលនៅជាសង្ឃនាយក) បានមានថេរដីកាថា មហាណាក មហាភូ និងអាចារ្យសន ។ល។ នៅខេត្តបាត់ដំបង បានប្រែចេញពីបឋមសម្ពោធិវិត្ថាររបស់សម្តេចក្រុម**ព្រះបរមានុជិត ជិនោរស** ក្នុងសម័យ**ព្រះយ៉ាកថា ថន** "តទាធរ" ឈុម ធ្វើជាចៅមឿង (ចៅហ្វាយក្រុង) ខេត្តបាត់ដំបង ហើយដែលបានផ្សព្វផ្សាយ។

នៅប្រទេសកម្ពុជា បុណ្យវិសាខបូជានេះ តាមដែលចាស់ទុំ អ្នកមុខ អ្នកការទាំងឡាយតំណាលតៗគ្នាបានឱ្យដឹងមកថា គេបានផ្តើមធ្វើក្នុងនៅរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី "ព្រះអង្គឌួង" ដែលគង់នៅក្នុងក្រុងឧដុង្គជាដំបូង ព្រោះថាកាលក្នុងពុទ្ធសករាជ ២៣៩៧ គ្រិស្តសករាជ ១៨៥៤ សម្តេចព្រះអង្គឌួង ទ្រង់សព្វព្រះរាជហឫទ័យស្នើសុំទូទៅក្នុងកម្ពុជរដ្ឋ។

៣. ហៅថា "បឋមសម្ពោធិកថា" គឺបឋមសម្ពោធិវិត្ថារនោះឯងដែលព្រះឥន្ទមុនី "**ប៉ែន**" គង់នៅវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ប្រែនិងរៀបរៀងចេញពីច្បាប់របស់សម្តេចព្រះមហាសង្ឃរាជ "**សា**" ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មានចំនួន ៣០ បរិច្ឆេទ ដូចច្បាប់ដើម។ គម្ពីរនេះមានជាបែបបទសម្រាយ ទេសនាក្នុងថ្ងៃវិសាខបូជា ក្នុងវត្តគណៈធម្មយុត្តិកនិកាយទូទាំងប្រទេសខ្មែរ។

ការធ្វើបុណ្យវិសាខបូជា ក្នុងសម័យរជ្ជកាលទី២ នោះ ប្រហែលជាមានធ្វើតែក្នុងក្រុង មិនទាន់បានផ្សព្វផ្សាយទៅគ្រប់វត្ត

អាពាមនៅឡើយទេ ហើយក៏មិនទាន់មានភាពឱឡារិកអធិកអធមណាស់ណាដែរ។

ពុទ្ធសាសនិកប្រទេសថៃ បានអះអាងថា ប្រពៃណីធ្វើវិសាខបូជាដែលត្រឹមត្រូវតាមលក្ខណៈ កើតមានឡើងតាំងពីត្រឹមរជ្ជកាលទី៤ ដោយព្រះរាជាអង្គនេះជាអ្នកប្រាជ្ញក្នុងផ្លូវ ព្រះពុទ្ធសាសនា ទ្រង់ចេះគម្ពីរព្រះត្រៃបិដកជ្រៅជ្រះ ទ្រង់បានផ្ដើមធ្វើវិសាខបូជាតាំងពីទ្រង់ព្រះផ្នួសនៅឡើយ។ លុះដល់ទ្រង់ដាក់ព្រះផ្នួសមកទទួលរាជសម្បត្តិ ក៏ទ្រង់នៅតែបន្តធ្វើវិសាខបូជារៀងដរាបមក រហូតដល់ទ្រង់បញ្ជាឱ្យរៀបចំគម្ពីរសម្រាយទេសនានៅក្នុងពិធីបុណ្យនេះដូចបានពោលខាងលើ។ ព្រះ**មហាប៉ាន** គឺសម្ដេច**ព្រះសុគន្ធាធិបតី** ជាគណៈធម្មយុត្តិកនិកាយ នៅក្នុងក្រុងទេព "បាងកក" អំពីព្រះបាទសម្ដេច**ព្រះចមក្លាវ** "រជ្ជកាលទី៤"។

បន្ទាប់មកក្រោយនោះមួយឆ្នាំ គឺនៅក្នុងពុទ្ធសករាជ ២៣៩៨ ព្រះមហា **ប៉ាន** ទើបនិមន្តមកអំពីទីក្រុងទេព ព្រះបាទសម្ដេចព្រះហរិរក្ស ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ហើយបាននិមន្តឱ្យគង់នៅជាចៅអធិការវត្តសាលាគូ ហៅ**វត្តអម្ពិលបី** នៅក្រុងឧដុង្គតរៀងមក។ ដោយហេតុថា ព្រះមហាថេរអង្គនេះ កាលដែលលោកគង់នៅទីក្រុងទេព ធ្លាប់ធ្វើវិសាខបូជារួចមកហើយ ហើយកាលបានគង់នៅប្រទេសខ្មែរ ព្រមទាំងបានធ្វើជាធំនៅក្នុង គណៈធម្មយុត្តិកនិកាយផង លោកក៏ផ្ដើមឡើងតាមដែលធ្លាប់ធ្វើកន្លងមក។ ប៉ុន្តែ យើងពុំបានដឹងច្បាស់ថា នៅពេលដំបូងនោះ តើលោកចាប់ផ្ដើមធ្វើក្នុងឆ្នាំណាសករាជប៉ុន្មាននោះទេ ព្រោះគ្មានឯកសារជាក់ស្ដែង គ្រាន់តែមានសេចក្ដីអះអាងពីអ្នកមុខ អ្នកការទាំងឡាយថាប្រាកដជាមានធ្វើវិសាខបូជា តាំងពីក្នុងពេលដែលលោកគង់នៅក្រុងឧដុង្គមកម៉្លេះ។ លុះដល់ពេលលោកមកគង់នៅវត្តបទុមវតី ក្រុងភ្នំពេញ ក្នុងពុទ្ធសករាជ ២៤០៨ ក៏បានប្រារព្ធវិសាខបូជារហូតដល់អស់ព្រះជន្ម។

ពិធីវិសាខបូជាត្រូវបានផ្សព្វផ្សាយទូទៅនៅគ្រប់វត្តគណៈធម្មយុត្តិកនិកាយជាប់ជាទំនៀមរហូតមក។ ចំណែកវត្តខាងមហានិកាយ ទើបមានធ្វើក្នុងសម័យក្រុងភ្នំពេញ ក្នុងរជ្ជកាលព្រះស៊ីសុវត្ថិ។ តាមដែលសម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជ **ជួន ណាត** (កាលនៅព្រះសង្ឃនាយក)

តំណាលថា ក្នុងឆ្នាំមួយនោះលោកគ្រូព្រះវនរ័ត**ចន្ទ** គង់នៅវត្តឧណ្ណាលោម បាននិមន្តទៅក្រុងទេព ឃើញព្រះសង្ឃនៅក្រុងនោះទាំងគណៈធម្មយុត្តិកនិកាយ ទាំងគណៈមហានិកាយធ្វើវិសាខបូជា ក៏កើតជ្រះថ្លានៅពេលនិមន្តត្រឡប់មកវិញ បានក្រាបបង្គំទូលសម្តេចព្រះមហាសង្ឃរាជ "**ព្រះនាមទៀង**" សុំឱ្យធ្វើវិសាខបូជា។ សម្តេចព្រះមហាសង្ឃរាជ**ទៀង** ក៏ទ្រង់បានព្រះរាជានុញ្ញាតតាមសំណូមពរ ទើបវិសាខបូជាត្រូវបានធ្វើជាបន្តបន្ទាប់រៀងដរាបមក។ ប៉ុន្តែពេលនោះក៏ពុំទាន់បានធ្វើគ្រប់វត្តនៅឡើយ គឺមានធ្វើចំពោះតែវត្តនៅក្នុងក្រុង។ ឯវត្តនៅតាមខេត្តក្រៅមានធ្វើតែវត្តធំៗ វត្តតូចៗ ច្រើនពុំបានធ្វើនៅឡើយ។

ចំណែកព្រះមហាក្សត្រដែនដី តាំងពីរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស "**ព្រះអង្គឌួង**" មកសុទ្ធតែទ្រង់ជ្រះថ្លាបានទទួលធ្វើគ្រប់ៗព្រះអង្គ ។

តាមឯកសារបានលើកសរសើរព្រះគុណសម្បត្តិព្រះបាទសម្តេចព្រះហរិរក្ស ដែលជាអ្នកផ្តួចផ្តើមធ្វើបុណ្យវិសាខបូជាឡើងជាដំបូង ពីព្រោះរាជាអង្គនេះ ទ្រង់ធ្លាប់ទៅគង់នៅក្នុងក្រុងទេព "បាងកក" និងទ្រង់ធ្លាប់សាងព្រះផ្នួសនៅទីនោះ។ ទ្រង់បានសិក្សាព្រះបរិយត្តិធម៌ ជ្រួតជ្រាបគម្ពីរព្រះត្រៃបិដកជ្រៅជ្រះ។ នៅពេលដែលទ្រង់បានឡើងសោយរាជសម្បត្តិ ក៏ទ្រង់ផ្តើមធ្វើពិធីបុណ្យនេះតាមដែលទ្រង់ធ្លាប់បានជ្រួតជ្រាប និងធ្លាប់បានទតឃើញ របៀបបែបផែនដែលគេធ្វើនៅក្រុងទេព ទើបជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃ។

## ២. របៀបធ្វើវិសាខបូជា

មុននឹងប្រកាសវិសាខបូជា លោកអាចារ្យនាំឧបាសក ឧបាសិកា និងពុទ្ធបរិស័ទនមស្ការព្រះរតនត្រ័យតាមវិធីរតនប្បណាមសង្ខេប ឬពិស្តារ ហើយសមាទានសីលរួច ក៏ប្រកាសវិសាខបូជា ដោយលោកអាចារ្យបានផ្តើមអានមួយឃ្លាម្តងៗ ដើម្បីឱ្យឧបាសកឧបាសិកា និងពុទ្ធបរិស័ទថាតាមថា៖ ***នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។ សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។ ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សំដែងនូវ***

ធម៌ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធ ពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវ ព្រះសម្មាសម្ពុទ្ធ អង្គនោះដោយគោរព ។ (ថ្វាយបង្គំជាលើកទី១)

និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។ ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយ បង្គំនូវព្រះធម៌ដោយគោរព ។ (ថ្វាយបង្គំជាលើកទី២)

សុបដិបន្នោ វត តស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម ។ ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកំចាត់បង់ នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័កនៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃមែនពិត យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះអរិយសង្ឃដោយគោរព។ (ថ្វាយបង្គំលើកទី៣ )

ថ្ងៃនេះជាតិថី[៥] ពេញបូណ៌មីនៃខែវិសាខ មានព្រះចន្ទ័ពេញវង់ ត្រូវនឹងថ្ងៃដែលព្រះសក្យមុនីសម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រសូត ទ្រង់បានត្រាស់ ជាព្រះសព្វញ្ញុពុទ្ធប្រាកដឡើងក្នុងលោក និងថ្ងៃដែលទ្រង់រំលត់ខ័ន្ធ ចូលកាន់បរិនិព្វាន។ តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តមក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជាចំពោះ ព្រះសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការបូជា មានទៀន មានធូប និងផ្កាជាដើមក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា យើងខ្ញុំសូម

[៥] តិថី ឬ ដិថី សំ.; បា. (ន.) (តិថិ ឬ តិថី; តិថិ) ថ្ងៃ(មួយៗ) ក្នុងមួយខែដែលរាប់តាមដំណើរព្រះចន្ទ ។

ព្រះពុទ្ធរូបស្នងព្រះអង្គ ក្តីគោរព បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន កាលឥឡូវនេះជាថ្ងៃពេញបូណ៌មីខែពិសាខ ប្រកបដោយនក្ខត្តសម័យ ដូចសម័យរបស់ព្រះដ៏មានព្រះភាគជាម្ចាស់នៃយើងនោះប្រាកដ ។ ត្បិតថាព្រះលោកនាយកជាម្ចាស់នៃយើង កាលទ្រង់ប្រសូតចាកគភ៌( ព្រះមាតា ) ក្នុងថ្ងៃសុក្រ ពេញបូណ៌មី ខែពិសាខ ឆ្នាំចនោះក្តី ត្រាស់ដឹងសព្វញ្ញុត្តញ្ញាណ ក្នុងថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកានោះក្តី ទ្រង់បរិនិព្វាន ក្នុងថ្ងៃអង្គារ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់នោះក្តី មានហើយដោយពិត។ ព្រោះហេតុនោះ (កាលឥឡូវនេះ ) យើងខ្ញុំទាំងឡាយ រឭកនូវនក្ខត្តសម័យនោះរបស់ព្រះអង្គ ទើបនាំគ្នាមកជួបជុំក្នុងទីនេះ ធ្វើបូជាដោយគ្រឿងសក្ការផ្សេងៗមានប្រទីប ធូបទៀន និងកម្រងផ្កាជាដើមផង បូជាដោយធម៌ផង។ បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ដែលទ្រង់បរិព្វានហើយ សូម្បីអស់កាលជាយូរអង្វែងហើយក្តី សូមព្រះអង្គទទួលនូវគ្រឿងបណ្ណាថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គលរបស់ទេវតានិងមនុស្សក្នុងលោកឥត មានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គ ទ្រង់បរិនិព្វានបាត់រូបព្រះកាយអស់កាលដ៏យូរអង្វែងហើយក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ថានព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូបស្នងព្រះអង្គក៏នៅមានប្រាកដដែរ។ សូមព្រះដ៏មានបុណ្យជាបរមសាស្តា ទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការបូជារបស់យើង ខ្ញុំព្រះអង្គដែលបានរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើងខ្ញុំព្រះអង្គបានប្រកបដោយ ឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចម្រើនដ៏ធំទូលាយ អស់កាលជាយូរអង្វែងទៅ ។ ( ថ្វាយបង្គំម្តង )

*ការទាំងនេះ ដែលទុគ្គតបណ្ណាការ[៦]របស់យើងខ្ញុំទាំងឡាយ ដើម្បីធ្វើឱ្យសាសនារុងរឿង ស្ថិតស្ថេរទៅផង ដើម្បីជាប្រយោជន៍ និងសេចក្តីសុខផង ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង។*

*លុះចប់វិធីប្រកាសវិសាខបូជានេះហើយ ព្រះសង្ឃទាំងអស់នមស្ការព្រះរតនត្រ័យតាមវិធីត្រៃប្រណាម និងធម៌សម្រាប់នមស្ការផ្សេងៗទៀតតាមដែលអាចសូធ្យបានគ្រប់ព្រះអង្គ។ បន្ទាប់មកទៀតគឺនិមន្តធម្មកឋិកសម្តែងធម៌ទេសនា។ លុះចប់ធម៌ទេសនា ពុទ្ធបរិស័ទណាចេះសូធ្យធម៌បទផ្សេងៗ ដែលស្របនឹងពិធីបុណ្យនេះ ដូចជានមោ៨បទ និងធម៌បទដែលពិពណ៌នាអំពីពុទ្ធប្បវត្ត ជាដើម។*

## ៣. ហេតុអ្វីបានជាត្រូវប្រារព្ធធ្វើថ្ងៃវិសាខបូជា?

*ការដែលត្រូវប្រារព្ធធ្វើថ្ងៃវិសាខបូជានេះ ព្រោះថ្ងៃនេះជាថ្ងៃដែលកត់សម្គាល់ដល់ហេតុការណ៍អស្ចារ្យ៣យ៉ាង ដែលកើតឡើងផ្ទួនគ្នាទាក់ទងនឹងខ្សែជីវិតរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គឺមានន័យថា ថ្ងៃនេះពុទ្ធសាសនិកជននៅទូទាំងពិភពលោកនាំគ្នារឭកនឹកដល់ថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វានរបស់ព្រះបរមសាស្តា។ ពាក្យថា "វិសាខបូជា" មកពីពាក្យថា "វិសាខបុណ្ណមីបូជា" ប្រែថា ការបូជាក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ គឺខែទី ៦ ដោយរាប់ពីខែមិគសិរ បុស្ស មាឃ ផល្គុន ចែត្រ ពិសាខជាដើម។*

*ការដែលប្រារព្ធពិធីបូជានាថ្ងៃ១៥កើត ខែពិសាខ នេះ អាស្រ័យដោយលោកអ្នកប្រាជ្ញខាងពុទ្ធសាសនា បានកំណត់ទុកក្នុងគម្ពីរបឋមសម្ពោធិកថា ជាមហាមង្គលអភិលក្ខិតកាល គឺជាថ្ងៃមហាមង្គល ត្រូវនឹងថ្ងៃដែលព្រះសម្ពុទ្ធបរមគ្រូ៖*

***១- ព្រះអង្គ ទ្រង់ព្រះប្រសូតចាកពីព្រះឧទរព្រះមាតា*** *៖ នៅពេលដែលព្រះនាងសិរិមហាមាយាទេវី ដែលជាព្រះអគ្គមហេសីរបស់ព្រះគម្តែងផ្ទៃក្រោមសុទ្ធោទននៃពជជានីកបិលពស្តុដែនសក្កៈ ទ្រង់គភ៌ហៀបនឹង*

[៦] ទុគ្គតបណ្ណាការ (ទុក-គៈតៈប៉ុន-ណា-កា) ន. (បា.; សំ. ទុគ៌ត + បណ៌ាការ) បណ្ណាការ, ភ័ស្តុភារ (តង្វាយ, ជំនូន) របស់អ្នកក្រីក្រ : វត្ថុទាំងនេះជាទុគ្គតបណ្ណាការរបស់យើងខ្ញុំ...។

*ដល់ថ្ងៃប្រសូតិកម្ម ព្រះនាងក៏លាព្រះស្វាមី ធ្វើដំណើរទៅកាន់មាតុនគរ គឺទេវទហៈ ដើម្បីសម្រាលព្រះរាជឱរសតាមទំនៀម និយមរបស់ព្រាហ្មណ៍ក្នុងសម័យនោះ។ លុះ ធ្វើដំណើរដល់ព្រំដែនឈ្មោះឧទ្យានលុម្ពិនី វ័ន(រម្មិណ្ឌេ) រវាងនគរកបិលពស្តុ និងទេវ ទហនគរ ទើបឈាងចូលទៅសម្រាកព្រះ កាយក្រោមដើមសាលព្រឹក្ស ។*

*នៅខណៈនោះ ព្រះនាងក៏សម្រាល ព្រះរាជឱរសក្រោមដើមសាលព្រឹក្សនោះ ឯង ដែលត្រូវនឹងពេលព្រឹកថ្ងៃសុក្រ តិថី ១៥ កើត ខែពិសាខ ឆ្នាំច មុនពុទ្ធសករាជចំនួន ៨០ឆ្នាំ។*

*លុះស្តាប់ឮដំណឹងថាព្រះមហេសី បានប្រសូតព្រះរាជឱរសដូច្នោះ **ព្រះសុទ្ធោទនៈ**ក៏ត្រាស់បញ្ជាឱ្យក្បួនដង្ហែ ដង្ហែព្រះ មហេសីនិងបុត្រត្រឡប់ចូលព្រះនគរវិញ។*

*កាលបើប្រសូតបានចំនួន៥ថ្ងៃគត់ ព្រះរាជឱរសអង្គនេះក៏ត្រូវបានសន្មតឱ្យព្រះ នាមថា **សិទ្ធត្ថៈ** ប្រែថា **អ្នកសម្រេច ប្រយោជន៍ដល់សត្វលោកទាំងពួង**។*

***២- ថ្ងៃព្រះអង្គត្រាស់ដឹងនូវអនុត្តរ សម្មាសម្ពោធិញ្ញាណ*** *៖ ក្រោយពីព្រះអង្គ ចេញសាងព្រះបួសបានចំនួន៦ព្រះវស្សា ស្ថិតក្នុងព្រះជន្ម៣៥ ព្រះវស្សា ព្រះសមណ សិទ្ធត្ថអង្គនោះ បានប្រព្រឹត្តនូវតបធម៌ ហើយ ប្រព្រឹត្តនូវទុក្ករកិរិយាមក ព្រះអង្គបានត្រាស់ ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ស្ថិតក្នុង ថ្ងៃពុធ ពេញបូណ៌មី (១៥កើត) ខែវិសាខ ឆ្នាំ រកា នៅក្នុងស្រុកឧរុវេលា ប្រទេសសេនា និគម ក្បែរស្ទឹងនេរញ្ជរា វេលាព្រឹកព្រាង ទៀបភ្លឺ ក្នុងព្រះជន្ម៣៥ឆ្នាំ នៅឯពុទ្ធគយា។*

***៣- ជាថ្ងៃព្រះយាងចូលព្រះបរមបរិនិព្វាន*** *៖ ក្រោយអំពីព្រះអង្គត្រាស់ដឹង និង ផ្សព្វផ្សាយព្រះធម៌អស់រយៈពេល៤៥ព្រះ វស្សា រហូតដល់ព្រះជន្មបាន៨០ព្រះវស្សា ហើយ ព្រះអង្គក៏ចូលបរិនិព្វាន ហើយនៅ ពេលទ្រង់រំលត់ព្រះខន្ធចូលកាន់ព្រះបរម និព្វាន គឺក្នុងថ្ងៃអង្គារ ពេញបូណ៌មី (១៥ កើត) ខែវិសាខ ឆ្នាំម្សាញ់ វេលារាត្រីជិតភ្លឺ ក្នុងព្រះជន្មគម្រប់៨០ឆ្នាំគត់ នឹងមុនពុទ្ធ សករាជ១ថ្ងៃគត់ ព្រះអង្គបរិនិព្វានក្នុងសាល វ័នឧទ្យាន ចន្លោះដើមរាំងទាំងគូ ក្បែរនគរ កុសិនារា។*

*ការដែលពោលថាជាហេតុការណ៍ដ៏ អស្ចារ្យ ពីព្រោះសម្តេចព្រះបរមសាស្ត្រាចារ្យ*

របស់យើង ព្រះអង្គប្រសូត ត្រាស់ដឹង និងបរិនិព្វាន នៅថ្ងៃ ១៥ កើត ខែ ពិសាខ ដូចគ្នា ទោះបីជាថ្ងៃខាងសុរិយគតិ និងឆ្នាំខាងចន្ទគតិខុសគ្នាក៏ដោយ ក៏ចាត់ថាជាហេតុការណ៍អស្ចារ្យបាន ព្រោះមនុស្សភាគច្រើនកើតនិងស្លាប់នៅតិថីនិងខែខាងចន្ទគតិផ្សេងៗគ្នា ប៉ុន្តែព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាននៅតិថី និងខែខាងចន្ទគតិដូចគ្នា ចាត់ទុកថាជាអច្ឆរិយបុគ្គលដែលគួរជាចងចាំនៃពិភពលោក។

ក៏ព្រោះហេតុនោះហើយបានជាអ្នកប្រាជ្ញចងក្រងជាគាថាទុកដូច្នេះថាៈ អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេ យេវ និក្ខមិ វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។ សេចក្តីថា ៖ ព្រះពុទ្ធយាងចុះកាន់គភ៌នៃព្រះវរមាតាក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ទ្រង់ប្រសូតក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ បានត្រាស់ដឹងជាព្រះពុទ្ធក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ និងទ្រង់ចូលបរិនិព្វាន ក៏ថ្ងៃពេញបូណ៌មី ខែពិសាខ(ផ្សេងតែឆ្នាំ)។ ជាប្រពៃណីពិធីវិសាខបូជា គេតែងតែនាំគ្នាធ្វើនៅក្នុងវេលារាត្រី ពីព្រោះតម្រូវទៅតាមពាក្យថា "បុណ្ណមី" មានសេចក្តីថា ខែពេញបូណ៌មី។

## ៤. សារៈសំខាន់នៃថ្ងៃវិសាខបូជា

១. ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃកំណើតរបស់ព្រះពុទ្ធសាសនា

២. ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃដែលអង្គការសហប្រជាជាតិ ទទួលស្គាល់ជាផ្លូវការតាមសម្នើរបស់ពុទ្ធបរិស័ទនៅក្នុងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ថាពិធីបុណ្យវិសាខបូជានេះ គឺជាពិធីបុណ្យអន្តរជាតិមួយដែលគេអាចប្រារព្ធធ្វើទៅតាមការិយាល័យទាំងឡាយរបស់អង្គការសហប្រជាជាតិទូទាំងពិភពលោក ហើយក៏ជាបុណ្យរបស់អន្តរជាតិផងដែរ។

ក្នុងសម័យប្រជុំអន្តរជាតិនៃក្រុមប្រឹក្សាផ្នែកពុទ្ធសាសនា ស្តីអំពី "**ទិវា-យូអិន-វិសាខា**" ឬ "**បុណ្យវិសាខបូជានៃអង្គការសហប្រជាជាតិ**" នេះ បានចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ២០០៤ នៅក្នុងប្រទេសថៃ។ តាំងពីពេលនោះមក សន្និសីទអន្តរជាតិនេះ បានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ប៉ុន្តែភាគច្រើនតែធ្វើនៅមុនថ្ងៃ១៥កើត ខែពិសាខ ដែលជាថ្ងៃបុណ្យវិសាខបូជា។ ប្រទេសថៃបានទទួលរៀបចំកិច្ចប្រជុំនេះជាច្រើនលើកមកហើយ។ រីឯប្រទេសវៀតណាម ក៏បានស្ម័គ្រទទួលនាទី

រៀបចំនូវសន្និសីទស្ដីអំពី "**ទិវា-យូអិន-វិសាខា**" នេះចំនួនពីរដង រួចមកហើយដែរ គឺកាលពីអំឡុងឆ្នាំ ២០១៣ និងឆ្នាំ២០០៨។

៣. ថ្ងៃវិសាខបូជានេះ គឺចាត់ជាថ្ងៃសន្តិភាពពិភពលោក ព្រោះព្រះសម្មាសម្ពុទ្ធជាម្ចាស់បង្រៀនមនុស្សជាតិឱ្យចេះស្វែងរកសន្តិសុខ និងសន្តិភាពទាំងខាងក្នុង និងខាងក្រៅ។

៤. ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃរំឭកគុណ គឺព្រះមហាករុណាគុណ ព្រះវិសុទ្ធិគុណ និងព្រះបញ្ញាគុណរបស់ព្រះ**សមណគោតម** ដែលជាព្រះបរមសាស្ដានៃលោក។

៥. ថ្ងៃវិសាខបូជា ចាត់ជាថ្ងៃព្រះពុទ្ធ ព្រោះទាក់ទងនឹងខ្សែជីវិតព្រះពុទ្ធជាម្ចាស់។

ជាសរុបសេចក្ដីមក ពិធីបុណ្យពិសាខបូជានេះ ជាពិធីបុណ្យមួយដែលពុទ្ធសាសនិកប្រារព្ធធ្វើឡើង ដើម្បីរម្លឹកដល់ព្រឹត្តិការណ៍ដ៏ពិសេសចំនួន៣ ដែលទាក់ទងនឹងព្រះសម្មាសម្ពុទ្ធ គឺការប្រសូត ការត្រាស់ដឹង និងការចូលនិព្វាន ដែលចំក្នុងថ្ងៃតែមួយ គឺថ្ងៃ១៥កើត ពេញបូណ៌មី ខែវិសាខ ដូចគ្នា គឺខុសតែឆ្នាំប៉ុណ្ណោះ ហើយដែលជាពិធីបុណ្យមួយមានលក្ខណៈអន្តរជាតិផងដែរ។

ដូច្នេះក្នុងនាមប្រទេសមួយដែលមានព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ តោងយើងទាំងអស់គ្នា សិក្សាស្វែងយល់ ថែរក្សា ការពារ និងប្រកាន់ខ្ជាប់ក្នុងការប្រារព្ធពិធីបុណ្យនេះ ឱ្យបានគត់មត់បរិសុទ្ធល្អ៕

## ឯកសារពិគ្រោះ


. ជួន ណាត *វចនានុក្រមខ្មែរ*

. ពេជ សល់ ***ពិធីប្រចាំដប់ពីរខែ ក្រុមប្រជុំទនៀមទម្លាប់ខ្មែរ*** ឆ្នាំ១៩៦៦។

. មិន ឃិន *ប្រជុំបុណ្យក្នុងព្រះពុទ្ធសាសនា និង* ***ទំនៀមទម្លាប់ខ្មែរ*** ក្រសួងធម្មការនិងសាសនា ឆ្នាំ ២០១០។

. ស្រី ធម្មានុន ***អ្វីខ្លះពុទ្ធសាសនិកជឿ*** (ប្រែសម្រួលដោយ ឈន អៀម) ឆ្នាំ២០១៨។

. ស្វែងយល់ពីប្រវត្តិ និងអត្ថន័យ «***បុណ្យពិសាខបូជា***» ក្នុងព្រះពុទ្ធសាសនា។

. អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប ***ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ (២០០៧)*** បោះពុម្ពនៅភ្នំពេញ ដោយរោងពុម្ពហនុមានទេសចរណ៍។